81

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥១៤ អនក្រ.បក

04.05.11

# អនុក្រឹត្យ

ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ឈឹម ឈន** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ១ ពីអភិបាលរងខេត្តតាកែវ ទៅជាអភិបាលរងខេត្តកំពង់ឆ្នាំង ជំនួសលោក **ហ៊ីង សារិន្ទ** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ២ :** ត្រូវបានតែងតាំងមុខតំណែងមន្ត្រីរាជការ ០២រូប ជាអភិបាលរងនៃគណៈអភិបាលខេត្តតាកែវ និងខេត្តស្ទឹងត្រែង ដូចមានរាយនាមខាងក្រោម :

១-លោក **គាន់ ឧុត្ត៏** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៧ ជាអភិបាលរងខេត្តតាកែវ ជំនួសលោក **ឈឹម ឈន** ។

២-លោក **ជឹន សុធា** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ១ ជាអភិបាលរងខេត្តស្ទឹងត្រែង ជំនួសលោក **គោត សំអេន** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ និងមាត្រា២ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*ដូចមាត្រា ៤*
*ឯកសារ កាលប្បវត្តិ*